# ពាក្យហៅសាច់ញាតិ ក្នុងសិលាចារឹកខ្មែរ (ភាគ៣)

នៅក្នុងអត្ថបទភាគ១និងភាគ២ មានបង្ហាញអំពីពាក្យហៅញាតិជា ជីដូនជីតា ឪពុកម្ដាយ បងប្អូន កូនចៅ តាមរយៈសិលាចារឹករួចមកហើយ[១]។ នៅក្នុងអត្ថបទភាគ៣ នេះ យើងនឹងបង្ហាញពាក្យហៅញាតិក្នុងសិលាចារឹកបុរាណជាបន្តទៅទៀត។

**ទួតៈ** ពាក្យនេះ យើងពុំទាន់ប្រទះឃើញនៅក្នុងសិលាចារឹកសម័យកណ្ដាលនៅឡើយទេ។ នៅសម័យអង្គរ មានសំណេរជា ***ទ្វត** និង ***ទ្វាត** ចំណែកនៅអន្តរកាលរវាងចុងសម័យមុនអង្គរនិងដើមសម័យអង្គរ មានសំណេរជា **ទ្វោត**។ ខាងក្រោមនេះជាដំណាក់ស្រង់ឧទាហរណ៍ពីសិលាចារឹកវត្តសសរ១០០ ខេត្តក្រចេះ៖

> «កន្ទេងកម្រតេងអញ៑តប្បោង កូនិកន្ទេងកម្រតេងអញ៑ត្រីជយេន្ទ្រភា ចៅកន្ទេងអញ៑ត្រីន្ទ្របេន្ទ្រទេវី **ចៅទ្វោត**វ្រះកម្រតេងអញ៑ត្រិន្ទ្រលោក» (K.១២៤៖ បន្ទាត់ទី៣-៦)។ ឃ្លានេះអាចប្រែសម្រួលបានថា «កន្ទេងគម្ដែងអញ(ជាកូន)ច្បង កូនរបស់កន្ទេងគម្ដែងអញស្រីជយេន្ទ្រភា ចៅរបស់កន្ទេងអញស្រីទ្រីបេន្ទ្រទេវី **ចៅទួត**របស់ព្រះគម្ដែងអញស្រិន្ទ្រលោក»។

**មាៈ** នៅសម័យមុនអង្គរនិងអង្គរ ពាក្យនេះមានសំណេរជា **អ្មា** ដែលបង្កើតឡើងដោយពាក្យ ***មា** និងផ្នត់ដើម /អ-/ ដូចពាក្យ **អ្ជិ/អ្ជី** និង **អ្តា** ដែរ[២]។ សូមពិនិត្យឧទាហរណ៍ដកស្រង់ពីសិលាចារឹកគោកប្ញស្សី K.១៧៥ ផ្ទាំងខាងជើងដូចខាងក្រោម៖

> «នេះបុន្យអ្ជិស្តេញ៑គិវាចាយ៌្យមោកិប្រទ្វាន្ទតិ**អ្មា**ស្តេញ៑គិវាចាយ៌្យតជ្មះលោញ៑កាម តជ្មះលោញ៑វលទេវ តជ្មះលោញ៑ហរិយ អន្វយិតគិនុកុលេថ្វេចំនតិ៑អ្វលិ» ដែលអាចប្រែសម្រួលបានថា «នេះ(ជា)បុណ្យរបស់ស្ដេញសិវាចារ្យដរាបមក។ ឪពុកមារបស់ស្ដេញ

---

[១] សូមមើល៖ https://ams.com.kh/khmercivilization/detail/18744 និង https://ams.com.kh/khmercivilization/detail/18900 ។

[២] សូមអាន៖ https://ams.com.kh/khmercivilization/detail/18744 ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

> សិវាចារ្យដែលឈ្មោះលោញកាម ឈ្មោះលោញពលទេព ឈ្មោះលោញហរិយ រស់នៅជាមួយនិងក្រុមគ្រួសារបានធ្វើចំណត/ចំណាត់ជាច្រើនកន្លែង»។

**អ៊ំ៖** នៅសម័យបុរាណ យើងឃើញមានប្រើពាក្យ **អេ្ប** និង **បេ** មានន័យដូចពាក្យ **អ៊ំ** នាពេលបច្ចុប្បន្ននេះ។ ពាក្យនេះ គេពុំស្គាល់ប្រភពច្បាស់លាស់ថាមានប្រភពមកពីភាសាណាឡើយ។ ពាក្យ **អ៊ំ** នេះនៅតំបន់មួយចំនួននិយមប្រើជា **ធំ** និងជាទូទៅប្រើជា **ឪពុកធំ ម្ដាយធំ** ដែលពាក្យ **ធំ** នេះផ្ទុយនឹងពាក្យ **មីង**។ ខាងក្រោមនេះជាសម្រង់ឃ្លាឧទាហរណ៍ពីសិលាចារឹកប្រាសាទបន្ទាយព្រាវ K.២២១ ផ្ទាំងខាងត្បូង៖

> «មនិខ្ញោញវលតុរងកេតិតអ្រៀកំស្តេង **អេ្ប**ខ្ញោញវលតុរងម្វាយទៅតកំស្តេងគិបិជូនិស្រុកិមធុរាបូរនុគណាឃោសំវារិតវ្រះកម្រតេងអញ្ជគិរលិង្គ» ដែលមានន័យថា «ខ្ញោញពលតុរងកើត(ជាមួយ)បងរបស់កំស្តែង, ឪពុកមានរបស់ខ្ញោញពលតុរងម្នាក់ទៅ(ជួបនិង)កំស្តែងដើម្បីជូនស្រុកមធុរាបូរនិងក្រុមរបស់ឃោសំវារ ថ្វាយចំពោះព្រះគម្តែងអញ្ជសិវលិង្គ»។

**មីង៖** តាមន័យដើមរបស់ពាក្យ, **មីង** មានន័យថា **ក្មេង**។ ពាក្យ **ក្មេង** ក៏ជាពាក្យកម្ចាយមកពីឫស **មីង** ផងដែរ។ នៅសម័យមុនអង្គរ ពាក្យនេះមានសំណេរជា **មេង** និង **ម្យង** ដែលនៅសម័យអង្គរ មានសំណេរជា **ម្យង**។ លុះមកដល់សម័យកណ្ដាលមានសំណេរជា **មិង មីង** និង **មឹង**។ ជាធម្មតា ពាក្យនេះប្រើជាទូទៅជា **ម្ដាយមីង** មានន័យថា**ម្ដាយតូច** ផ្ទុយនឹង **ម្ដាយធំ** និងប្រើខ្វីជា **មីង**។ ខុសប្លែកពីពាក្យ **ធំ** ដែលប្រើជា **ឪពុកធំ**, ពាក្យ **មីង** មិនប្រើជា **ឪពុកមីង** នោះទេ។ ដូច្នេះហើយទើបពាក្យ **មីង** ប្រើសម្គាល់តែម្ដាយតូច ឬប្អូនស្រីរបស់ម្ដាយឪពុកតែប៉ុណ្ណោះ។ ក្នុងសិលាចារឹកសម័យកណ្ដាលមានប្រើពាក្យ **ម្ដាយមីងបង្កើត** (IMA៣៩) ដូចបច្ចុប្បន្នដែរ។ នៅសម័យអង្គរ តាមរយៈសិលាចារឹកគោកសំរោង K.២៣៩ ផ្ទាំងខាងត្បូង មានប្រើពាក្យ **មេម្យង** = **មេមីង** ដូចក្នុងឃ្លាថា៖ «វាបិគោនុតាញ៉ិតនិនុ**មេម្យង**តាញ៉ិតន្ទ» មានន័យថា «វាបគោនិងតាញតន និងម្ដាយមីងតាញតន»៕

(នៅមានត)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## បញ្ជីរូបភាព







អត្ថបទដោយៈ ហ៊ុន ឈុនតេង៍